# កម្ពុជសុរិយា


ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ បោះពុម្ពផ្សាយ
អំពីពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រៈ ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម, បណ្ឌិត នៅ
ពុទ្ធសាសនបណ្ឌិត្យ
បណ្ណាធិការ ផ្នែកដំណឹងសាសនាៈ ព្រះទេពសត្ថា សួរ-ហាយ
ក្រុមជំនុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ



| ផ្នែកអក្សរសាស្ត្រ | បញ្ជីរឿង | ទំព័រ |
| --- | --- | --- |
| នាងទេត្រ-ឡាំងសី | របរថ្នាំជក់ | ៣២១ |
| លោក ភ៊ាយ-ប៊ុត ក្រមការ | សុភាសិត ភាគ ១ (តមក) | ៣៣១ |
| — | ប្រជុំពាក្យព្រេងនិងបារាំង (តមក) | ៣៣៥ |
| ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម | សព្ទបារាំង ប្រែជាខ្មែរ | ៣៤១ |
| — | ប្រវត្តិសាស្ត្រសង្ខេប ប្រទេសឥណ្ឌៀ (តមក) | ៣៤៥ |
| អ្នកឧកញ៉ា នូ-កន | រឿងសាមកុក (តមក) | ៣៥៣ |

| ផ្នែកសាសនា | | |
| --- | --- | --- |
| ព្រះបាឡាត់ សុង-ស៊ុំ | ត្រៃកូដធម៌ | ៣៦៣ |
| ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម | គន្ធីអាសីទិប (តមក) | ៣៧៥ |

| កំណត់ហេតុប្រវត្តិការណ៍ | | |
| --- | --- | --- |
| ភិក្ខុ ឡេង-ឈួន | ប្រវត្តិព្រះមហា រស់-កោ | ៣៨១ |
| ភិក្ខុ សួន-ស៊ុំន | បុណ្យបូជាសពអ្នកអាចារ្យហ៊ុំន-សុង (តមក) | ៣៨៦ |
| ក្រសួងធម្មការ | អំពីការតាំងហៅអធិការថ្មី (តមក) | ៣៩៥ |

## ទ្រៃញ្ញជជម៉

### វិទ្យុធម្មទេសនា ព្រះបាឡាត់ចន្ទមុណីរ័ត សុខស៊ីវ វត្តលង្កា

---

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

សូមនមស្ការចំពោះព្រះភគវន្តមុនី អរហំសម្មាសម្ពុទ្ធ ព្រះអង្គនោះ (ព្រមទាំងព្រះធម៌ហើយនឹងព្រះអរិយសង្ឃ ដោយគោរព) ។

វេលានេះអាត្មាភាពសូមដកស្រង់យកធម៌បីយ៉ាងគឺ: សច្ចំ សេចក្ដីពិតត្រង់ ១, ខន្តី សេចក្ដីអត់ធន់ ១, កតញ្ញុតា សេចក្ដីដឹងគុណ ១, ធម៌ទាំងបីនេះមានសំដែងជាបុគ្គលាធិដ្ឋាន ក្នុងគម្ពីរមហាបដ្ឋាន ត្រង់សរូបចតុត្តិសតិបច្ចយការៈ ជាធម្មសវនាការដូចតទៅនេះ:

ធម៌ទាំងបីគឺ:សច្ចំ, ខន្តី, កតញ្ញុតានេះ ឈ្មោះថាត្រៃកូដធម៌ ឬឧត្តមវរធម៌ ឬថា បធានធម៌ ព្រោះធម៌ជាកំពូលនៃលោកប្រសើរវិសេសធំចម្បងជាងធម៌ទាំងពួង ។

### សេចក្ដីអធិប្បាយ

ទី ១— សច្ចំ សេចក្ដីពិតត្រង់ គឺមិននិយាយបំផ្លើសឲ្យលើសពីសភាវៈពិត បើឃើញថាឃើញ ខុសថាខុស, ត្រូវថាត្រូវដូច្នេះជាដើម ហៅថាសច្ចៈសេចក្ដីពិត បើសំដែងដោយឧក្រិដ្ឋបានដល់អរិយសច្ចទាំង ៤, ពាក្យថា អរិយសច្ចនេះប្រែថា សេចក្ដីពិតរបស់ព្រះអរិយបុគ្គល, សេចក្ដីពិតឥតល្អៀងមាន៤យ៉ាងគឺ: ១— ទុក្ខ: សេចក្ដីព្រួយលំបាក,

២–សមុទយៈ កំណើតទុក្ខ ឬហេតុដែលនាំឲ្យកើតទុក្ខ, ៣– និរោធៈ សេចក្តីរលត់ទុក្ខ ឬធម៌សម្រាប់រលត់ទុក្ខ, ៤– មគ្គៈ ផ្លូវឬឧបាយនៃសេចក្តីរលត់ទុក្ខទាំង៤យ៉ាងនេះ ជាសច្ចៈពិតតតមានទល្អៀងនឹងបំបែរទៅជាមិនពិតទៅវិញពុំបានឡើយ ។

ក៏សច្ចៈធម៌នេះព្រះសម្មាសម្ពុទ្ធទ្រង់សំដែងដោយពិស្តារក្នុងសុត្តន្តបិដក គម្ពីរមជ្ឈិមនិកាយ មជ្ឈិមបណ្ណាសកៈ ត្រង់ចង្កីសូត្រ ក្នុងសូត្រនោះមានសេចក្តីដំណាលថាៈ មានមាណពម្នាក់ឈ្មោះកាបទិកៈ មានក្បាលកោររលីងមានអាយុ ១៦ ឆ្នាំពីកំណើត រៀនចប់ត្រៃវេទ ព្រមទាំងគម្ពីរនិឃណ្ឌុនិងគម្ពីរកេដុភៈ ព្រមទាំងអក្ខរប្បភេទ គឺសិក្ខានិងនិរុត្តិ ដែលមានគម្ពីរឥតិហាសៈជាគំរប់ ៥ ជាអ្នកស្ទាល់នូវបទនិងវេយ្យាករណ៍ ជាអ្នកមិនទន់ថយ គឺស្ទាត់ជំនាញក្នុងលោកាយតសាស្ត្រ និងមហាបុរិសលក្ខណព្យាករណសាស្ត្រ, បានសួរគេធម៌ដែលនាំឲ្យកើតសច្ចៈចំពោះព្រះមានព្រះភាគ ។ ទ្រង់ឆ្លើយតបថាៈ ម្នាលកាបទិកៈ សច្ចៈគឺសេចក្តីពិតត្រង់កើតឡើងដោយអាស្រ័យការព្យាយាម ។ កើតឡើងដោយអាស្រ័យការពិចារណា ។ កើតឡើងដោយអាស្រ័យការប្រឹងប្រែង ។ កើតឡើងដោយអាស្រ័យឆន្ទៈការពេញចិត្ត ។ កើតឡើងដោយអាស្រ័យការចូលចិត្តធម៌ក្នុងគំនិត ។ កើតឡើងដោយអាស្រ័យការពិចារណានូវអត្ថ ។ កើតឡើងដោយការចេះចាំនូវធម៌ ។ កើតឡើងដោយអាស្រ័យការស្តាប់ធម៌ ។

កើតឡើងដោយអាស្រ័យការផ្ចង់ត្រចៀកប្រុងស្តាប់ៗ កើតឡើងដោយអាស្រ័យការចូលទៅអង្គុយជិតៗ កើតឡើងដោយការចូលទៅរកៗ កើតឡើងដោយអាស្រ័យសទ្ធាសេចក្តីជឿៈ បើបុគ្គលណាគ្មានសទ្ធាហើយ ការចូលទៅរកក៏មិនមាន, ការចូលទៅអង្គុយជិតក៏មិនមាន, ការផ្ចង់ត្រចៀកប្រុងស្តាប់ក៏មិនមាន, ការស្តាប់ធម៌ក៏មិនមាន ការចេះចាំនូវធម៌ក៏មិនមាន, ការពិចារណានូវអត្ថក៏មិនមាន, សេចក្តីចូលចិត្តធម៌ក្នុងគំនិតក៏មិនមាន, ឆន្ទៈការពេញចិត្តក៏មិនមាន, ការប្រឹងប្រែងក៏មិនមាន, ការពិចារណាក៏មិនមាន, សេចក្តីព្យាយាមក៏មិនមាន, សច្ចៈសេចក្តីពិតត្រង់ក៏មិនមាន, បុគ្គលនោះលែងស្គាល់ខុសត្រូវ, គុណទោស, បុណ្យ-បាប លុះទៅក្នុងអំណាចនៃលោភៈ, ទោសៈ, មោហៈ ការណ៍ដែលមិនពិតហាក់ជាពិត, សេចក្តីខុសហាក់ជាត្រូវ គិតឃើញតែប្រយោជន៍ផ្ទាល់ខ្លួន មិនឃើញសេចក្តីទុក្ខរបស់អ្នកដទៃៈ មនុស្សបែបនេះនឹងក្លាយខ្លួនទៅជាអប្បេសក្ខបុគ្គល រកស្លូតគំនិតក្លានឈានសមាបត្តិមិនឃើញឡើយ. ពីព្រោះសព្វសត្វទាំងអស់ក្នុងពិភពលោក ដែលមានមុខឆ្ពោះសព្វរទៅរកខ្លួនធម៌បាន ដោយសារតែមានសច្ចៈជាបន្ទាល់ជួយទល់ទ្រ បើប្រាសចាកសច្ចៈហើយ នឹងរកខ្លួនធម៌មិនឃើញឡើយ ។ ដូចជាក្នុងលោកសព្វថ្ងៃនេះ បើប្រទេសណាមិនមានសច្ចៈធម៌ដល់គ្នានឹងគ្នា គឺពួកពលរដ្ឋគ្មានសច្ចៈពិតត្រង់ចំពោះព្រះមហាក្សត្រនិងពួកសេវកាមាត្យ ។

ក៏គ្មានសច្ចៈពិតត្រង់ចំពោះព្រះមហាក្សត្រនឹងពលរដ្ឋទេ ប្រទេសនោះមិនអាចឋាត់ធ៌ស្ថាពរបរិបូណ៌ដោយមហិទ្ធិរិទ្ធិឡើយ មុខជានឹងស្គមស្គិតត់តប្អិអំណាចពួកវិទេសជនទាំងឡាយ នឹងជិះជាន់គេគេរផញ្ជក់យកសាច់ឈាម នឹងក្លាយទៅជាប្រទេសទាបទាសទុគ៌តភាពមិនខាន ។

មួយទៀតសម្បូរមាតាបិតានឹងបុត្រាបុត្រី ស្វាមីនឹងភរិយា ឬគ្រូឧបជ្ឈាយាចារ្យនឹងសិស្សានុសិស្ស បើគ្មានសច្ចៈពិតត្រង់ទៅវិញទៅមកទេ សេចក្ដីវិនាសតែងកើតឡើងប្រាកដដល់ជនទាំងឡាយនោះ ។ សច្ចៈធម៌នេះជាគុណប្រសើរបំផុតក្នុងលោកបានជាព្រះសម្ពុទ្ធជាអគ្គបុគ្គលទ្រង់សំដែងថា: **សច្ចំ ហិ បរមំ លោកេ សច្ចំ លោកេ បធានកំ សច្ចម្ហិ តិដ្ឋមានស្មឹ សព្វបុញ្ញាញ្ញ តិដ្ឋតិ ។** សេចក្ដីថាសច្ចៈជាធម៌ដ៏ឧត្ដមក្នុងលោក សច្ចៈជាប្រធានក្នុងលោក ក៏បុណ្យទាំងអស់រមែងមានក្នុងសច្ចៈ ។ បើប្រាសចាកសច្ចៈហើយបុណ្យក៏មិនមាន បើគ្មានបុណ្យហើយ រមែងបានជួបតែនឹងសេចក្ដីទុក្ខលំបាកល្វីងខ្លៅក្រីក្រថោកទាបជានិច្ច; ព្រោះហេតុនោះលោកអ្នកសប្បុរសទាំងឡាយគួរទំញាំងសច្ចៈគឺសេចក្ដីពិតត្រង់ឲ្យកើតមានឡើងគ្រប់ៗ គ្នា ។

ទី ២ — ខន្តី សេចក្ដីអត់ធន់ទុកជាបន្ទូលទីពីរសម្រាប់ទល់ទ្រស្ទួយសត្វឲ្យមានមុខឆ្ពោះទៅរកអរិយធម៌; ខន្តិ ប្រែថាសេចក្ដីអត់ជាគួននឹងតិតិក្ខា

ប្រែថាសេចក្ដីធន់ សត្វទាំងពីរនេះមានសេចក្ដីជាមួយគ្នា ទើបរួមចូលគ្នា ហៅថាសេចក្ដីអត់ធន់ សេចក្ដីអត់ធន់នេះលោកចែកជាបីយ៉ាងគឺ:

១ — អត់ធន់ចំពោះសេចក្ដីទុក្ខដែលជាហេតុឲ្យកើតលោភៈ,

២ — អត់ធន់ចំពោះសេចក្ដីទុក្ខដែលជាហេតុឲ្យកើតទោសៈ,

៣ — អត់ធន់ចំពោះសេចក្ដីទុក្ខដែលជាហេតុឲ្យកើតមោហៈ ។

ឯការអត់ធន់ចំពោះសេចក្ដីទុក្ខដែលជាហេតុឲ្យកើតលោភៈនោះបាន ខាងការអត់ទ្រាំនឹងចំណង់ផ្សេងៗដែលកើតឡើងក្នុងទ្វារទាំង៦ ។ ពាក្យថាអត់ទ្រាំគឺមិនប្រព្រឹត្តទុច្ចរិតតាមចំណង់ ឬសេចក្ដីស្រេកឃ្លាននោះៗ ។ បុគ្គលចំពួកខ្លះព្រោះតែមិនចេះអត់ទ្រាំនឹងចំណង់ ឬសេចក្ដីស្រេកឃ្លាន បានជាហ៊ានលួចឆក់ដណ្ដើមបំបាត់ប្រវ័ញ្ចទ្រព្យសម្បត្តិរបស់គេ កាលបើប្រព្រឹត្តដូច្នោះ រមែងជួបប្រទះនឹងសេចក្ដីទុក្ខព្រួយដែលជាផលរបស់ទុច្ចរិតនោះៗ មានត្រូវទោសជាប់គុកច្រវាក់ជាដើម ។ បុគ្គលណាជាមនុស្សមិនសូវរវះរវាមពេក ចេះអត់ទ្រាំបាន បុគ្គលនោះឯងតែងប្រកបដោយសុខភាពនឹងអនាម័យល្អ ។ ខន្តិ សេចក្ដីអត់ធន់បែបនេះ ហៅថាអត់ធន់ចំពោះសេចក្ដីទុក្ខដែលជាហេតុឲ្យកើតលោភៈ សូម្បីអត់ធន់ចំពោះសេចក្ដីទុក្ខដែលជាហេតុឲ្យកើតរាគៈ គួរសង្គ្រោះចូលក្នុងខន្តីនេះដែរ ។ ឯសេចក្ដីអត់ធន់ចំពោះសេចក្ដីទុក្ខដែលជាហេតុឲ្យកើតទោសៈនោះ បានខាងសេចក្ដីអត់ធន់នឹងពាក្យបរបោក ដែលបុគ្គលដទៃស្ដីថា រិះគន់បុគ្គ

តិះដៀល ឬអត់ធន់នឹងអំពើដែលបុគ្គលដទៃបៀតបៀនដែលជាហេតុឲ្យកើតទោសៈ ។ ធម្មតាមនុស្សដែលកើតមកក្នុងលោកសន្និវាសនេះ ដែលចាំមិនឲ្យគេស្តីថាមិនឲ្យគេរិះគន់ ឬតិះដៀលនោះគ្មានទេ. អម្បាលព្រះអាទិត្យព្រះចន្ទ ដែលទ្រង់បំភ្លឺលោកជាប្រក្រតី ម្តេចក៏គង់មានគេតិះដៀលទូរដែរ, ចំណង់បើមនុស្សក្នុងលោកនឹងរកនរណាឲ្យជាមនុស្សឥតគេតិះដៀលនោះមិនមានឡើយ; ទុកជាព្រះសាស្តាបរមគ្រូជាម្ចាស់ដែលប្រកបដោយព្រះមហាករុណាទិគុណ ក៏គង់មានគេតិះដៀលទូរដែរ, បើយល់ជាក់យ៉ាងនេះហើយគួរឲ្យមានខន្តីអត់ធន់កុំក្រោធខឹង ។ បុរាណាចារ្យទាំងឡាយ លោកសំដែងប្រាប់ប្រាយ គឺយោបល់ជាគ្រឿងរំលត់សេចក្តីក្រោធខឹងថា: "ទុកជាមានភ្នែកភ្លឺក៏ត្រូវធ្វើដូចជាងងឹត, មានត្រចៀកស្តាប់ឮ ក៏ត្រូវធ្វើដូចជាថ្លង់" ដូច្នេះទើបអត់ធន់សេចក្តីក្រោធខឹងនោះបាន, ប្រសិនបើធ្វើជាមនុស្សភ្នែកទិព្វត្រចៀកទិព្វ ចេះតែឃើញចេះតែឮ ហើយនៅជាបុថុជ្ជនចិត្តស្រាលផង ក៏នឹងរក្សាខន្តី សេចក្តីអត់ធន់នោះបានដោយកម្រណាស់ ។

ឯការអត់ធន់ចំពោះសេចក្តីទុក្ខ ដែលជាហេតុឲ្យកើតមោហៈនោះ បានខាងសេចក្តីអត់ធន់នឹងទុក្ខវេទនាផ្សេង ៗ ដែលកើតឡើងក្នុងកាយនិងចិត្ត មិនលុះក្នុងអំណាចទុក្ខវេទនា ហើយទៅប្រព្រឹត្តទុច្ចរិតឡើយ ។ សូម្បីការដែលអត់ទ្រាំនឹងទុក្ខវេទនាក្នុងវេលាឈឺចាប់នោះសោត ក៏ជា

ហេតុដូច្នេះបុគ្គល ឲ្យមានសតិសម្បជញ្ញៈ គឺសេចក្តីភ្ញាក់រឭកនឹងសេចក្តីដឹងខ្លួន ដែលជាគុណវិសេសគួរឲ្យមានគ្រប់កាលទាំងពួង, ពុំនោះសោតក្នុងវេលាមានព្យាធិដែលជាហេតុឲ្យដល់មរណៈ ក៏ត្រូវតែមានខន្តីយ៉ាងនឹងមាំមួនខានមិនបានឡើយ ។ ឧបាយដែលនឹងឲ្យកើតខន្តិក្នុងវេលានោះ គឺត្រូវតែតែងឲ្យឃើញតាមសេចក្តីពិតថា ព្យាធិនឹងមរណៈនោះ ជាទុក្ខដែលសត្វទាំងឡាយត្រូវតែជួបប្រទះរាល់ៗគ្នា គេចមិនរួចឡើយ; ក្នុងអភិណ្ហ-បច្ចវេក្ខណៈ ដែលព្រះបរមសាស្តាទ្រង់ប្រដៅឲ្យនឹករំពឹងជារឿយៗថា: "ព្យាធិធម្មោម្ហិ ព្យាធឹ អនតីតោ" អាត្មាអញមានជម្ងឺជាធម្មតា នឹងចៀសវាងជម្ងឺជាតមិនបានឡើយ" ដូច្នេះនោះ ក៏គប្បីឲ្យប្រុងខ្លួនអំពីកាលដែលនៅជានៅឡើយ; បើចាំទៅនឹករំពឹងក្នុងពេលដែលជម្ងឺជាតមកដល់តែម្តង ក៏មុខជាកម្រនឹងបាន, ព្រោះវេលាដែលឈឺនោះឯងតែងមានទុក្ខព្រួយលំបាកច្រើនយ៉ាងណាស់; កាលបើអត់-ទ្រាំទុក្ខវេទនាមិនបាន សតិសម្បជញ្ញៈក៏នឹងទ្រេតទ្រោតទៅមិនតាំងនៅខ្ជាប់ឡើយ, ដូចជនជំពូកខ្លះដែលមិនបានហាត់ចិត្តទុកអំពីកាលនៅជានោះ លុះវេលាដែលមានជម្ងឺយ៉ាងធ្ងន់មកដល់ ក៏ច្រើនតែមានចិត្តរវើរ-វាយឆ្វេងៗ ឆកាបដល់ធ្វើអំពើទុច្ចរិតខានសម្លាប់សត្វជាដើម ដើម្បីបូជាគ្រោះ ដោយចង់រស់តែខ្លួនឯង មិនគិតករុណាតសត្វដទៃក៏មាន ។ ព្រោះហេតុដូច្នោះ ការដែលបណ្តុះចិត្តបណ្តុះស្មារតី ដើម្បីឲ្យកើតខន្តី

នោះ ជាកិច្ចដែលយើងត្រូវការគ្រប់ៗ ប្រាណសម្រាប់តយុទ្ធនឹងសត្រូវ គឺតណ្ហា និងទុក្ខ គ្រប់វេលាដែលជិតនឹងដល់មរណៈទុក្ខនោះ ។ ចំណែកអ្នកដែលមានប្រាជ្ញារៀនគេខ្វះគាត់ទៀត ទាំងវិទ្យាសាស្ត្រ មានអក្សរសាស្ត្រ ភូមិសាស្ត្រ និងពាណិជ្ជកម្ម កសិកម្មជាដើម បើមានខន្តីអត់ធន់ខ្ជាប់ ការស្រេកឃ្លាន មានត្រ ក្តៅត្រជាក់ជាដើមហើយ វិជ្ជានឹងកើតឡើង ក៏រមែងនឹងសម្រេចដល់បុគ្គលនោះដោយមុហុត្តភាព បុគ្គលនោះនឹងធ្វើខ្លួនឲ្យទៅជាមនុស្សចំរើនលោកបាន ។ ម្យ៉ាងទៀតអ្នកដែលមានខន្តីរមែងជាទីប្រិយនៃទេវតានឹងមនុស្សទាំងឡាយ. សមនឹងពុទ្ធភាសិតថា:

**ខន្តិកោ មេត្តវា លាភី យសស្សី សុខសីលវា បិយោ ទេវមនុស្សានំ មនាបោ ហោតិ ខន្តិកោ** “អ្នកមានខន្តីជាអ្នកមានមេត្តា ជាអ្នកមានលាភ ជាអ្នកមានយស ជាអ្នកមានសេចក្តីសុខជាប្រក្រតី អ្នកមានខន្តីរមែងជាទីស្រឡាញ់ជាទីគាប់ចិត្តនៃទេវតានឹងមនុស្សទាំងឡាយ” ។ ខន្តីនេះជាគុណធម៌ប្រសើរបំផុតក្នុងលោក ព្រះសម្ពុទ្ធជាម្ចាស់ទ្រង់សំដែងថា: **ខន្តិ ហិ បរមំ លោកេ ខន្តិ លោកេ បធានគា ខន្តិយា វឌ្ឍមានាយ សព្វបុញ្ញំ វឌ្ឍតិ** ។ សេចក្តីថា “ខន្តីជាធម៌ដ៏ឧត្តមក្នុងលោក ខន្តីធម៌ជាប្រធានក្នុងលោក ក៏បុណ្យទាំងអស់មានដោយសារខន្តី” ។ បើប្រាសចាកខន្តីហើយរមែងនឹងជួបតែនឹងសេចក្តីទុក្ខ លំបាកក្រីក្រ ចោក

តាមផាន់ប៉ុះ ព្រោះហេតុនោះលោកអ្នកសប្បុរសទាំងឡាយ គួរចំរើន ខន្តិធម៌ឲ្យមានឡើងគ្រប់ៗគ្នា ។

ទី៣– កតញ្ញូតា សេចក្ដីដឹងគុណទុកជាចំនួលគំរប់សំរាប់ទល់ទំលើកសត្វឲ្យដល់នូវអនាគតភាពដ៏ល្អ ។ កតញ្ញូតាធម៌ជាគូនឹងកតវេទិតាធម៌ គឺបើដឹងថាអ្នកណាមួយមានគុណដល់ខ្លួន ហើយត្រូវធ្វើគុណតបអ្នកនោះវិញ បើគ្រាន់តែដឹងៗ តែប៉ុណ្ណោះ ក៏មិនអាចញុំាងប្រយោជន៍ឲ្យសម្រេចបាន ដូចជាដឹងថាព្រះពុទ្ធ, ព្រះធម៌, ព្រះសង្ឃ, មានគុណជាអនន្តចំពោះសព្វសត្វទាំងអស់ក្នុងត្រៃលោក សត្វទាំងនោះគួរតែតាំងចិត្តឲ្យស្មោះចំពោះព្រះពុទ្ធ; ព្រះធម៌, ព្រះសង្ឃយកជាទីពឹងទីរឭកស្មើដោយជីវិត ទាំងទំប្រតិបត្តិតាមឱវាទរបស់ព្រះសម្ពុទ្ធជាម្ចាស់ ពុំប្រព្រឹត្តកន្លងដូច្នេះជាដើម ឈ្មោះថាមានកតញ្ញូកតវេទិតាធម៌ចំពោះព្រះពុទ្ធ, ព្រះធម៌, ព្រះសង្ឃ; ព្រមទាំងដឹងគុណចំពោះបុព្វការីទាំងឡាយមានមាតាបិតាជាដើម ត្រូវតែរក្សាដោយស្មោះស្ម័គ្រ បើលោកមិនទាន់មានសទ្ធា, សីលៈ, ចាគៈ, បញ្ញាគប្បីឲ្យមានឡើង; បើបុគ្គលណាមួយប្រកបដោយកតញ្ញូកតវេទិតាធម៌ដូច្នេះហើយ បុគ្គលនោះឈ្មោះថាបិទនូវទ្វារនៃអបាយទាំង ៤ មាននិរយ៍ជាដើមនឹងបានប្រកបដោយសុខក្នុងអនាគតដ៏ល្អ ។ បុរាណបណ្ឌិតទាំងឡាយមានព្រះសម្ពុទ្ធជាដើមដែលទ្រង់ស្វែងរកគុណនេះសុខ លោក

មិនដែលលះបង់នូវកតញ្ញូកតវេទិតាធម៌នេះឡើយ ។ ដូចកាលព្រះសម្ពុទ្ធ ជាម្ចាស់ទ្រង់សោយព្រះជាតិជាស្តេចសេក ជួនជាប្រកបដោយអព្រៃគាត ទៅជាប់លប់អ្នកព្រៃ ហើយបានត្រឡប់រស់ជីវិតឡើងវិញ ក៏ដោយ សារតែគុណនៃកតញ្ញូកតវេទិតាធម៌ ។

មួយទៀតក្នុងប្រទេសនីមួយៗ ពួកពលរដ្ឋទាំងឡាយត្រូវមានកតញ្ញូ កតវេទិតាធម៌ចំពោះព្រះមហាក្សត្រ ស៊ូយកកម្លាំងកាយនិងកម្លាំងទ្រព្យ ជូនផ្ញើជាពលពលី ក្នុងពេលដែលកើតអសន្តិសុខម្តងៗ ក្នុងប្រទេស ហើយត្រូវស្រឡាញ់ព្រះមហាក្សត្ររបស់ខ្លួនស្មើដោយជីវិត, ត្រូវដឹង គុណពួកសេវកាមាត្យទាំងឡាយ ដែលបានថែរក្សាច្បាប់ ឲ្យប្រតិបត្តិ ដើម្បីបានសេចក្តីសុខចំរើន, បើពួកសេវកាមាត្យទាំងនោះមានកើតអ- សន្ទុ ដោយហេតុណាមួយត្រូវជួយដោយស្មោះស្ម័គ្រ ទាំងទំប្រតិបត្តិ តាមច្បាប់ ពុំហ៊ានប្រព្រឹត្តកន្លងនូវឧច្ចេះជាដើម ឈ្មោះថាមានកតញ្ញូកតវេទិ- តាធម៌ចំពោះសេវកាមាត្យ ។ ត្រូវប្រកបដោយមេត្តាករុណាប្រណីចំពោះ ពលរដ្ឋទាំងសកលរដ្ឋ ត្រូវកាន់សច្ចៈនិងខន្តិឲ្យខ្ជាប់កុំល្មើសក្នុងអំណាចនៃ អគតិធម៌ទាំង ៤ មានឆន្ទាគតិជាដើម ។

ក៏ធម៌ទាំងបីគឺសច្ចំ, ខន្តី, កតញ្ញូតានេះ បើមាននៅភូមិ, ស្រុក, ខេត្ត ប្រទេសណាហើយ ភូមិ, ស្រុក, ខេត្ត, ប្រទេសនោះនឹងសម្បូណ៌ដោយ

វេស្សនតាត ដាក់ធំល្អតណាស់ឡើងមានបុទ្ធិទ្រៀងដោយមុហុត្តកាល មិនអាចក្លាយទៅជាប្រទេសនាបរាសសត្រូវទេឡើយ, ដូចកំសំលោរស្តែដែលមានកំពស់ ៨ ហ៊ុន ២ ពាន់យោជន៍ ខ្ពស់ស្កឹមស្កៃលេចទៅក្នុងនគា-ល័យ នោះបើមានខ្យល់ព្យុះព្យាមាបក់បោកមកអំពីទិសទាំង ៨ ក៏មិនអាចញាំញីធ្វើភ្នំនោះឱ្យញាប់ញ័របានឡើយ ដោយមានឫសបង្គល់ទ្រទប់ពីក្រោមយ៉ាងណាមិញ ត្រៃគុណធម៌ទាំងបី នុកដូចជាបង្គល់ទល់ទ្រសត្វក្នុងពិភពលោកមិនឱ្យអនុវត្តទៅរកហិនភាពគឺផុតពោះវៃរ ។

ឯត្រៃគុណធម៌នេះកុំនិយាយឡើយដល់ទៅមនុស្ស នោះណាតិរច្ឆានក៏ដោយ ឲ្យតែចេះរក្សាទុកត្រៃគុណធម៌នេះដោយទៀងទាត់ប្រាកដ ក៏អាចធ្វើខ្លួនឲ្យក្លាយទៅជាទេវតាបាន ដូចមាននិទានមួយក្នុងពហលាតារិស្សូត្រ តម្ពែរមហាបង្ខាន ត្រង់សរុបចតុត្ថសតិបច្ចយការ: ដំណាលថា: មានសត្វបីគឺមេគោ១, កូនគោ១, ខ្លាធំ១, ជាអ្នករក្សានូវធម៌ទាំងបី, មេគោរក្សាសច្ចធម៌, កូនគោរក្សាកតញ្ញូតាធម៌, ខ្លាធំរក្សាខន្តិធម៌, ដោយអំ-ណាចធម៌ទាំងបី សត្វទាំងនោះ ក៏បានទៅសោយទិព្វសម្បត្តិនៅស្ថានត្រៃត្រឹង្សស្ថិតបរិបូណ៌ដោយយសបរិវារជាអស្ចារ្យ. រឿងនេះមិនបានប្រាប់ដោយពិស្ដារ សូមមើលក្នុងពហលាតារិស្សូត្រនោះចុះ; ត្រាន់តែដំណាលមកដោយខ្លីប៉ុណ្ណោះឲ្យឃើញថាធម៌ទាំងបីគឺ សច្ចំ, ខន្តិ, កតញ្ញូតានេះ

មានមហិទ្ធិឫទ្ធិគួរអស្ចារ្យ បើសំដែងដោយឧក្រិដ្ឋឃើញថាមានអត្ថដ៏ជ្រៅឆ្ងាយពន់ពេក ។

ន័យមួយទៀត ព្រះសម្ពុទ្ធទ្រង់សំដែងថា: សច្ចៈ រម្ងាប់លោភ:, ខន្តិ រម្ងាប់ទោស:, កតញ្ញូតា រម្ងាប់មោហ: ។

សំដែងមកក្នុងធម៌ទាំងបី គឺ សច្ចំ, ខន្តិ, កតញ្ញូតា ដែលហៅថា ត្រៃគុណធម៌ ឧត្តមវរធម៌ បុព្វបដានធម៌ ក៏សន្និដ្ឋានចប់ដោយសង្ខេបតែប៉ុណ្ណេះ ។

ធម្មទេសនានេះផង: ដោយតេជះនៃធម្មទេសនាសូមទេវតាទាំងមួយម៉ឺនលោកធាតុ ពិទ័ក្សរក្សាព្រះបរមមហាក្សត្រ ព្រមទាំងព្រះរាជវង្សានុវង្ស សម្តេចព្រះវររាជបិតា សម្តេចព្រះវររាជជននីនាថ សូមទ្រង់ប្រសិទ្ធដោយចតុព្វិធពរ គឺ អាយុ, វណ្ណ:, សុខ:, ពល:, បរិបូណ៌ដោយព្រះសតិបញ្ញាបរិហារកម្ពុជប្រទេស ឲ្យបានលុះដល់ឧត្តមគតិដោយមហុត្តកាលដ៏ស្រួលទាន់សម័យ: ទាំងសូមបរិស័ទទាំងឡាយគ្រប់ជាន់ ដែលបានប្រតិបត្តិតាមសាសនៈវង្ស ក្រោមអធិបតេយ្យនៃព្រះសម្មាសម្ពុទ្ធឲ្យបានប្រកបដោយសុខភាពអនាម័យដ៏ល្អ ដើម្បីជាពលរដ្ឋ ប្រកបកិច្ចសាសនាគាំពារបានមគ្គផលសមស័យសមតាមអធ្យាស្រ័យគ្រប់បំណងកុំបីឃ្លាតឡើយ ។

( ចប់ )

ព្រះបាឡាត់ឧត្តមលិខិត ( សុង - ស៊ុរ )